# ក្រសួងអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា នៃរដ្ឋ Massachusetts

75 Pleasant Street, Malden, Massachusetts 02148-4906
ទូរសព្ទ៖ (781) 338-3000
TTY: N.E.T. បញ្ជូនបន្ត 1-800-439-2370

Jeffrey C. Riley
*គណៈកម្មការ*

ខែកញ្ញា ឆ្នាំ 2023

ជូនចំពោះឪពុកម្តាយ/អាណាព្យាបាលជាទីគោរពអំពីថ្នាក់សិក្សាប្រចាំឆ្នាំ 2027៖

សិស្សថ្នាក់ទីប្រាំបួនដែលនឹងចូលរៀននៅឆ្នាំនេះបានចូលរៀននៅវិទ្យាល័យនៅពេលដែលរដ្ឋកំពុងតែផ្លាស់ប្តូរទៅកាន់ស្តង់ដារពិន្ទុជាប់ថ្មីសម្រាប់តម្រូវការ ក្នុងការកំណត់សមត្ថភាព (CD) តាម MCAS ក្នុងមុខវិជ្ជាសិល្បៈភាសា អង់គ្លេស (ELA) គណិតវិទ្យា និងវិទ្យាសាស្ត្រ។ ខ្ញុំសង្ឃឹមថាលិខិតនេះនឹងជួយបញ្ជាក់អំពីតម្រូវការសម្រាប់ការបញ្ចប់ការសិក្សាចំពោះការរៀនសូត្រនៃកូនរបស់អ្នក។

ក្នុងកិច្ចប្រជុំពិសេសរបស់ខ្លួននៅថ្ងៃទី 15 ខែសីហា ឆ្នាំ 2022 ក្រុមប្រឹក្សាអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាបានបោះឆ្នោតដើម្បីធ្វើបច្ចុប្បន្នភាពតម្រូវការនៃ CD ដែលនឹងចាប់ផ្តើមសិក្សាប្រចាំឆ្នាំ 2026។ ស្តង់ដារថ្មីនេះកំណត់យកពិន្ទុជាប់អប្បបរមានៅក្នុង ELA គណិតវិទ្យា និងវិទ្យាសាស្ត្រដើម្បីបញ្ចប់ការសិក្សាពីវិទ្យាល័យ។ សិស្សរៀនក្នុងសិក្សាឆ្នាំ 2026 ដល់ ឆ្នាំ 2030 ត្រូវបំពេញតាមតម្រូវការដូចខាងក្រោមដើម្បីមានសិទ្ធិទទួលបានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បន្ថែមពីលើការបំពេញតាមតម្រូវការសម្រាប់ការបញ្ចប់ការសិក្សាមូលដ្ឋានទាំងអស់)៖

- ទទួលបានពិន្ទុជាមាត្រដ្ឋានចំនួន 486 ពិន្ទុ ឬខ្ពស់ជាងនេះលើការធ្វើតេស្ត ELA និងគណិតវិទ្យា ឬការធ្វើតេស្តម្តងទៀត ឬ
- ទទួលបានពិន្ទុមាត្រដ្ឋានចំនួន 470-485 ពិន្ទុលើការធ្វើតេស្ត ELA និងគណិតវិទ្យា ឬការធ្វើតេស្តម្តងទៀត ហើយបំពេញតាមតម្រូវការនៃផែនការជំនាញអប់រំ (EPP) ក្នុងមុខវិជ្ជាទាំងនោះ (www.doe.mass.edu/assessment/epp) និង
- ទទួលបានពិន្ទុមាត្រដ្ឋានចំនួន 470 ពិន្ទុ ឬខ្ពស់ជាងនេះទេ ចំពោះតេស្តវិទ្យាសាស្ត្រក្នុងមុខវិជ្ជាជីវវិទ្យា ឬរូបវិទ្យាថ្នាក់ចាប់ផ្តើម។

សិស្សនឹងធ្វើតេស្ត ELA និងគណិតវិទ្យានៅថ្នាក់ទី 10 ហើយពួកគេមានសិទ្ធិធ្វើតេស្តមួយក្នុងចំណោមតេស្តវិទ្យាសាស្ត្រនៅថ្នាក់ទី 9ឬទី10។ សិស្សនឹងបន្តមានឱកាសធ្វើតេស្តម្តងទៀតចំពោះតេស្ត MCAS នៅវិទ្យាល័យ ហើយនឹងមានឱកាសដើម្បីមានលក្ខណសម្បត្តិគ្រប់គ្រាន់ទទួលបានក្រេឌីតថ្លៃសិក្សានៅមហាវិទ្យាល័យ ឬសាកលវិទ្យាល័យសាធារណៈនៃរដ្ឋ Massachusetts តាមរយៈការធ្វើតេស្ត MCAS នៅវិទ្យាល័យ។ ព័ត៌មានអំពីអាហារូបករណ៍មាននៅលើគេហទំព័រ www.doe.mass.edu/scholarships/mastery/koplik-adams-compare.html។

ប្រសិនបើអ្នកមានសំណួរអំពីតម្រូវការសម្រាប់ការបញ្ចប់ការសិក្សា សូមទាក់ទងអ្នកផ្តល់ប្រឹក្សា ឬនាយកសាលាដើម្បីណែនាំអំពីសាលារបស់អ្នក ឬក៏ចូលទៅមើលគេហទំព័រ www.doe.mass.edu/mcas/graduation.html ដើម្បីទទួលបានព័ត៌មានបន្ថែម។

ដោយក្តីគោរព

Jeffrey C. Riley
គណៈកម្មការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា